002/19-09-2007-ECCC/TC
**E1/336**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 10 / 09 / 2015
ម៉ោង (Time/Heure) : 14:10
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# **<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

**<u>សាធារណៈ</u>**

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ អង្គារ៍ ទី ២៥ ខែ សីហា ឆ្នាំ ២០១៥

## **សវនាការលើកសុតាង - ថ្ងៃ ៣១៧**

រៀបចំដោយ៖ **ឯម ហ៊ីយ** និង **Roger PHILLIPS**

| **<u>កំណត់ហេតុអ្នកចូលរួម</u>** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ , ចៅក្រម Jean-Marc LAVERGNE , ចៅក្រម យូ អូតារ៉ា |
| ចៅក្រមបម្រុង៖ ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោក ឯម ហ៊ីយ, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Joseph Andrew BOYLE , លោក ស្រ៊ា រតនៈ, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អារុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| | |
|---|---|
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោក ពេជ អង្គ | |
| សាក្សី/ដើមបណ្ដឹង៖ ញ៉ឹប ហល់ (2-TCCP-269) | |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ | |
| ផ្សេងៗ៖ លោក វ៉ាត សុម៉ៅ, លោកស្រី សំ មករា, កញ្ញា ពេជ ចរិយា, លោក កើយ វិញគៀម, កញ្ញា Aphra LEE | |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៨.៥៨ | បញ្ចប់ម៉ោង៖ ១៤.១៦ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១៤ | បញ្ចប់ម៉ោង៖ ១០.៣០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.២៩ | បញ្ចប់ម៉ោង៖ ១៣.២៨ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ គ្មាន | បញ្ចប់ម៉ោង៖ គ្មាន |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ម៉ោង ០៣ និង ០៣ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០០ | ០៩.០១ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០១ | ០៩.០២ |
| ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ញ៉ឹប ហល់ (2-TCCP-269) | អង្គជំនុំជម្រះ<br><br>សហមេធាវីនាំមុខ<br><br>សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ<br><br>មេធាវីការពារក្ដី នួន ជា | ០៩.០៣<br>០៩.០៧<br>១០.៣២<br><br>១០.៥២<br>១១.១៦<br><br>១៣.២៩ | ០៩.០៧<br>១០.១៤<br>១០.៥២<br><br>១១.១៥<br>១១.២៨<br><br>១៣.៤៨ |

| | | | |
|---|---|---|---|
| | មេធាវីការពារក្តី ខៀវ សំផន | ១៣.៤៩ | ១៤.០៧ |
| ការពិភាក្សាលើសំណួរទាក់ទងនឹងស្ថានភាព និងការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី | | ១០.០៤<br>១៣.៣៨ | ១០.៤៨<br>១៣.៥០ |
| ការថ្លែងអំពី ទុកសោក និង ព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហល់ (2-TCCP-269) | ដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហល់ | ១៤.០៧ | ១៤.១៣ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឲ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហល់ (2-TCCP-269)</u>**

អង្គជំនុំជម្រះបានតាំងសំណួរបឋមមួយចំនួនទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី (2-TCCP-269)។ បន្ទាប់មក សហមេធាវីនាំមុខ សហព្រះរាជអាជ្ញា មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន បានធ្វើការតាំងសំណួរជាបន្តទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី។

**<u>ការពិភាក្សាលើសំណួរទាក់ទងនឹងស្ថានភាព និង ការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី</u>**

សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងការរៀបការនៅកន្លែងការដ្ឋានការងារទំនប់ត្រពាំងថ្ម។ មេធាវីការពារក្តី នួន ជា បានធ្វើការជំទាស់

ថាតើសំណួរ ទាំងនេះមានឥទ្ធិពលទៅលើការទទួលយក ដើមបណ្ដឹងរដ្ឋប្បវេណីដែលទាក់ទង ដោយផ្ទាល់ទៅនឹងទំនប់ឬយ៉ាងណា។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានបញ្ជាក់ថា ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានទទួលយក ហើយការជំទាស់គួរត្រូវបានធ្វើឡើងនៅពេលស៊ើបអង្កេត។ សំណួរនេះគួរត្រូវបានអនុញ្ញាត ពីព្រោះជាផ្នែកមួយដែលមានការពាក់ព័ន្ធនឹងបទពិសោធដោយផ្ទាល់នៃដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងវិសាលភាពនៃការជំនុំជំម្រះ។ មេធាវីការពារក្ដី ខៀវ សំផន បានជំទាស់ទៅនឹងការសួរដេញដោលរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទៅលើអង្គហេតុដែលមិនមានជាប់ពាក់ព័ន្ធទៅពាក្យសុំតាំងខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ពួកគេគួរបែងចែករវាងសាក្សីធម្មតាដែលផ្ដល់សក្ខីកម្មចំពោះអង្គហេតុ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានឋានៈផ្សេងពីនេះ។

ប្រធានអង្គជំនុំជម្រះបាននិយាយថា ការការពារនេះគឺត្រឹមត្រូវ ដែលថាប្រសិនបើមនុស្សនៅទីនេះក្លាយជាដើមបណ្ដឹងរដ្ឋប្បវេណី គឺវាពាក់ព័ន្ធជម្រៅ វាពាក់ព័ន្ធជាសារវ័ន្ត គឺទំនាក់ទំនងនៃអង្គហេតុដែលនាំឱ្យទទួលព្យសនកម្ម និងសំណួរខ្លះពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានអះអាងថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ (E315/1) បានសម្រេចថា ដើមបណ្ដឹងរដ្ឋប្បវេណីអាចផ្ដល់សក្ខីកម្មទៅលើអង្គហេតុ ព្រមទាំងការទទួលរងនូវព្យសនកម្មផងដែរ។ ប្រធានអង្គជំនុំជម្រះបង្គាប់ឱ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដាក់សារណាជាលាយលក្ខណ៍អក្សរ។

នៅពេលរសៀល មេធាវីការពារក្ដី នួន ជា បានជម្រុញថា វាជាការចាំបាច់សម្រាប់ការការពារក្ដីចំពោះបញ្ហាប្រឈមនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ពីព្រោះ វាមិនទាន់រួចរាល់ដោយ សហចៅក្រមស៊ើបអង្កេត។ មេធាវីការពារក្ដី ខៀវ សំផន បានបញ្ជាក់ថា ការការពារក្ដីនេះមិនអាចតតាំងបានទេរវាងផលបះពាល់របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងអង្គហេតុដែលកំពុងធ្វើការដេញដោល ដោយសារដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានទទួលយកនៅក្នុងដំណាក់កាលមុខអង្គសេចក្ដី ។

អង្គជំនុំជម្រះបានបញ្ជាក់ថា សំណួរដែលសួរអំពីការទទួលយក ដើមបណ្ដឹងរដ្ឋប្បវេណី គួរសួរទៅការិយាល័យសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ។ សំណួរទាំងនោះ មិនគួរសួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។

<u>**ការថ្លែងរៀបរាប់អំពី ទុក្ខសោកវេទនា និង ព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ (2-TCCP-269)**</u>

ដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើការថ្លែងរៀបរាប់ អំពីការឈឺចាប់ ទុកសោក និងព្យសនកម្មផ្ទាល់ខ្លួនដែល

បានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃកិច្ចស៊ើបសួរ**

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/5018 | D22/3050 | 00560142-00560154; 01060036-01060039; 00897048-00897063 | Civil Party Application of NHIP Horl | P | 00560150 | 01060039 | 00897059 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០២)
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥។ (១៤.១៦)

**កាលវេលាសវនាការបន្ត**

សវនាការនឹងបន្តទៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

ឯម ហ៊ិយ Roger PHILLIPS